# ចំណាប់អារម្មណ៍

## របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា

## ក្នុងឱកាសពិធីសម្ពោធអគារសាលាឧទ្ធរណ៍

## ថ្ងៃ១០ ខែតុលា ឆ្នាំ២០១២

## ដោយលោកស្រី Marie-Dominique Parent តំណាងស្តីទី

សូមគោរព

ឯកឧត្តមសុខ អាន ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

និងជាសហប្រធានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

ឯកឧត្តម ឌិត មុន្ទី ប្រធានតុលាការកំពូល និងជាសហប្រធានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

ឯកឧត្តម អង្គ វង្សវឌ្ឍានា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ឯកឧត្តម ព្រហ្ម សុខា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ

ឯកឧត្តម យូ ប៊ុនឡេង ប្រធានសាលាឧទ្ធរណ៍

ឯកឧត្តម អ៊ុក សារ៉ុធ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

លោកជំទាវ Penny Richards ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំនៅកម្ពុជា

លោកជំទាវ ឯកឧត្តម លោកស្រី លោក ជាភ្ញៀវជាតិ និងអន្តរជាតិជាទីគោរពរាប់អាន

នេះគឺជាកិត្តិយសមួយដ៏ក្រៃលែងចំពោះការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាដែលមានវត្តមាននៅថ្ងៃដ៏មានសារសំខាន់នេះ។ ពិធីសម្ពោធអគារថ្មីសាលាឧទ្ធរណ៍ កត់សំគាល់ពីការចាប់ផ្តើមថ្មីមួយ។ មនុស្សជាច្រើនបានខិតខំធ្វើការយ៉ាងសកម្មក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដើម្បីធ្វើឲ្យមានថ្ងៃនេះកើតឡើង ហើយយើងខ្ញុំសូមចូលរួមអបអរសាទរចំពោះសាលាឧទ្ធរណ៍ មហាអយ្យការអមសាលាឧទ្ធរណ៍ និងមន្ត្រីទាំងអស់របស់ស្ថាប័ននេះ ដែលសក្តិសមបំផុតនឹងទទួលបាននូវសមិទ្ធផលនេះ។

អាណត្តិការងាររបស់ការិយាល័យឧត្តមស្នងការ គឺដើម្បីជួយអាជ្ញាធរក្នុងការបំពេញបាននូវកាតព្វកិច្ចសិទ្ធិមនុស្សរបស់ខ្លួន។ ក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ជនគ្រប់រូបមានសិទ្ធិស្នើសុំឲ្យដោះស្រាយរឿងក្តីរបស់ខ្លួនក្នុងពេលមួយដ៏សមស្រប និងស្នើសុំឲ្យតុលាការមួយខ្ពស់ជាងពិនិត្យឡើងវិញស្របតាមច្បាប់នូវការចោទប្រកាន់ និងការផ្តន្ទាទោសខ្លួន។ នៅពេលជនណាម្នាក់ត្រូវបានឃុំខ្លួន ពួកគេមិនគួរមើលឃើញរយៈពេលជាប់ឃុំរបស់ខ្លួនកើនឡើង ដោយសារគ្រាន់តែពួកគេរង់ចាំបណ្តឹងឧទ្ធរណ៍នោះទេ។

អស់រយៈពេលជាច្រើនឆ្នាំមកហើយ ដែលការិយាល័យយើងខ្ញុំមានការបារម្ភអំពីករណីនៃការឃុំខ្លួនយូរ ដោយសារតែមានជនជាប់ចោទច្រើន មិនថាតែពិរុទ្ធជន ឬជនដែលត្រូវលើកលែងចោទដោយសាលាដំបូងនោះទេ ពួកគេបានរង់ចាំអស់រយៈពេលយ៉ាងយូរ ដើម្បីឲ្យបណ្តឹងឧទ្ធរណ៍របស់ខ្លួន ត្រូវបានលើកយកមកជំនុំជម្រះ។ ប្រការនេះ ក៏បានក្លាយជាសេចក្តីកង្វល់ដោយឡែកមួយ ចំពោះកំរិតនៃភាពចង្អៀតណែននៅក្នុងពន្ធនាគារ ដែលកម្ពុជាកំពុងតែជួបជាបញ្ហាអស់ពេលជាច្រើនឆ្នាំមកនេះ ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងដ៏សំខាន់របស់រាជរដ្ឋាភិបាល ក្នុងការសាងសង់ពន្ធនាគារបន្ថែមទៀតក៏ដោយ។

ហេតុនេះហើយ បានជាការិយាល័យយើងខ្ញុំ មានការប្តេជ្ញាចិត្តខ្ពស់ចំពោះគំរោងនៃការពង្រឹកសមត្ថភាពសាលាឧទ្ធរណ៍។ យើងទាំងអស់គ្នាសុទ្ធតែមានការគាំទ្របែបនេះដូចគ្នា ដូចដែលយើងបានឃើញលទ្ធផលដែលសំរេចបានដោយសាលាឧទ្ធរណ៍ ក្នុងការកែលំអឲ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ក្នុងការប្រើប្រាស់ទីកន្លែងដែលមានស្រាប់របស់សាលាឧទ្ធរណ៍ និងការកែលំអការគ្រប់គ្រងសំណុំរឿង តាមរយៈប្រព័ន្ធទិន្នន័យថ្មី ដែលបង្កលក្ខណៈងាយស្រួលដល់សាធារណៈជនក្នុងការសាកសួរ និងតាមដាមសំណុំរឿងរបស់ខ្លួន។ លទ្ធផលទាំងនេះគឺសុទ្ធតែទទួលបាន ក្រោមការដឹកនាំរបស់ឯកឧត្តម យូ ប៊ុនឡេង និងមានការចូលរួមយ៉ាងសកម្មពីឯកឧត្តមអគ្គព្រះរាជអាជ្ញា ពីសំណាក់ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមន្ត្រីទាំងអស់របស់ស្ថាប័ននេះ។

ការិយាល័យយើងខ្ញុំ និងសាលាឧទ្ធរណ៍បានធ្វើការជាមួយគ្នាយ៉ាងជិតស្និទតាំងពីឆ្នាំ២០០៩ ដើម្បីកៀងគរម្ចាស់ជំនួយឲ្យគាំទ្រគំរោងនេះ។ នៅឆ្នាំ២០១០ ការិយាល័យយើងខ្ញុំ បានរៀបចំកិច្ចប្រជុំតុមូលនៃដៃគូអភិវឌ្ឍន៍ ដើម្បីអនុញ្ញាតឲ្យពួកគេ ស្តាប់បទបង្ហាញពីផែនការ និងសេចក្តីត្រូវការរបស់សាលាឧទ្ធរណ៍។ បន្ទាប់ពីកិច្ចប្រជុំតុមូលនៃអ្នកផ្តល់ជំនួយមក យើងត្រូវបានធ្វើឲ្យរំភើបចិត្តដោយដឹងថា រដ្ឋាភិបាលអូស្រ្តាលីបានឯកភាពដោយសប្បុរស ផ្តល់ថវិកាដែលចាំបាច់ ដើម្បីសាងសង់បន្ទប់ធ្វើការបន្ថែម ដើម្បីផ្តល់លទ្ធភាពដល់សាលាឧទ្ធរណ៍ ឲ្យដំណើរការកាន់តែប្រសើរ និងជំនុំជម្រះសំណុំរឿងឧទ្ធរណ៍បានទាន់ពេលវេលា។ ការិយាល័យយើងខ្ញុំ ក៏បានជួយផ្តល់សំភារៈមួយចំនួនដល់អគារថ្មីនេះ រួមមានគ្រឿងសង្ហារិម ប្រព័ន្ធសំលេង វីដេអូ កុំព្យូទ័រនិងសំភារៈការិយាល័យមួយចំនួនទៀត។ យើងមានការសប្បាយរីករាយមែនទែន នឹងឃើញអគារថ្មីនៃសាលាឧទ្ធរណ៍ថ្ងៃនេះ។ ហើយយើងក៏មានក្តីរីករាយផងដែរ ជាពិសេសដោយលឺថា មានការបើកសវនាការលើរឿងឧទ្ធរណ៍ កាន់តែច្រើនឡើង ដែលជាលទ្ធផលនៃសមិទ្ធផលនេះ។

ចាប់តាំងពីកិច្ចខិតខំប្រឹងប្រែងដំបូងនៅឆ្នាំ២០០៩រហូតដល់ថ្ងៃសម្ពោធក្នុងឆ្នាំ២០១២នេះ គឺវាស្មើតែ៤ឆ្នាំបានកន្លងផុតទៅហើយ។ ក្នុងរយៈពេល៤ឆ្នាំនេះ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សបានរក្សានូវការសន្យារបស់ខ្លួន គាំទ្រដល់ការវិវត្តន៍ក្នុងកំណែទម្រង់ច្បាប់ និងយុត្តិធម៌ ដើម្បីធ្វើឲ្យប្រព័ន្ធយុត្តិធម៌មួយរឹងមាំនៅកម្ពុជា និងការទទួលបានសេវាកម្មយុត្តិធម៌សំរាប់ទាំងអស់គ្នាកាន់តែប្រសើរ នៅ

ព្រះរាជាណាចក្រនេះ។ ក្នុងបណ្តាឆ្នាំទាំងនេះ យើងបានបន្តគាំទ្រ និងធ្វើការជាមួយតួអង្គពាក់ព័ន្ធទាំងអស់ ដើម្បីសំរេចបាននូវលទ្ធផលដ៏សំខាន់នេះ ដែលយើងកំពុងតែប្រារព្ធពិធីនៅថ្ងៃនេះ។

កិច្ចសហប្រតិបត្តិការរវាងការិយាល័យយើងខ្ញុំ និងសាលាឧទ្ធរណ៍ នៅតែមានជាបន្ត។ យើងធ្វើការយ៉ាងជិតស្និតជាមួយគ្នា ដើម្បីកំណត់ពីសំណុំរឿងអាទិភាពដែលត្រូវយកមកជំនុំជម្រះឲ្យបានមុនគេ ជាពិសេស សំណុំរឿងដែលជាប់បណ្តឹងឧទ្ធរណ៍យូរមកហើយផង។ នេះគឺជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងយ៉ាងទូលាយ រវាងសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ ដើម្បីបន្តការកែលំអដំណើរការតុលាការ និងជាពិសេសសហប្រតិបត្តិការរវាងតុលាការ អយ្យការ និងពន្ធនាគារ។

ក្នុងករណីនេះ សាលាឧទ្ធរណ៍បានផ្តួចផ្តើមគំនិតយ៉ាងសំខាន់ដើម្បីរៀបចំកិច្ចប្រជុំមួយកាលពីខែកន្លងទៅ ដោយមានការចូលរួមពីប្រធានពន្ធនាគារគ្រប់ខេត្ត-រាជធានី ប្រធានតុលាការ និងព្រះរាជអាជ្ញាគ្រប់ខេត្ត-រាជធានី ក្រោមការឧបត្ថម្ភពីការិយាល័យឧត្តមស្នងការ ដើម្បីពិភាក្សាគ្នាពីការបង្កើនកិច្ចសហការ និងចែករំលែកព័ត៌មានរវាងស្ថាប័នទាំងនេះ។ យើងខ្ញុំជឿជាក់ថា អនុសាសន៍បានពីការពិភាក្សាប្រកបដោយផ្លែផ្កាពីកិច្ចប្រជុំនេះ អាចធ្វើដំណើរលើផ្លូវដ៏វែងឆ្ងាយទៀតក្នុងការកែលំអកិច្ចសហការរវាងស្ថាប័ននីមួយៗ ហើយហេតុដូច្នេះ នឹងធ្វើឲ្យកាន់តែមានប្រសិទ្ធភាព និងភាពត្រឹមត្រូវនៃប្រព័ន្ធយុត្តិធម៌នៅកម្ពុជា។ រាជរដ្ឋាភិបាល បានទទួលយកអនុសាសន៍ជាច្រើនទាក់ទងនឹងវិស័យយុត្តិធម៌ នៅក្នុងកំឡុងពេលពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់របស់កម្ពុជានៅឯក្រុមប្រឹក្សាសិទ្ធិមនុស្សសហប្រជាជាតិ ក្នុងឆ្នាំ២០០៩។ យើងជឿជាក់ថា កិច្ចខិតខំប្រឹងប្រែងទាំងនេះ ចូលរួមចំណែកដល់ ការអនុវត្តតាមអនុសាសន៍ទាំងនេះ។

ការពង្រីកអគារថ្មីនៃសាលាឧទ្ធរណ៍នេះ គឺជាសក្ខីកម្មនៃការតាំងចិត្ត និងការប្តេជ្ញាចិត្តរួមគ្នារបស់សាលាឧទ្ធរណ៍ ក្នុងការកែលំអប្រព័ន្ធយុត្តិធម៌នៅកម្ពុជា ស្របតាមយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌របស់រាជរដ្ឋាភិបាល។ ហើយការិយាល័យយើងខ្ញុំមានមោទនភាពដែលអាចចូលរួមជួយចំពោះកិច្ចខិតខំប្រឹងប្រែងនេះ។

ការិយាល័យឧត្តមស្នងការ សូមវាយតំលៃខ្ពស់ចំពោះកិច្ចសហការដ៏យូរអង្វែងរបស់ខ្លួន ជាមួយសាលាឧទ្ធរណ៍ និងរាជរដ្ឋាភិបាលកម្ពុជា។ ការិយាល័យយើងខ្ញុំ ត្រៀមខ្លួនជាស្រេចដើម្បីបន្តផ្តល់ការគាំទ្រ និងជំនួយរបស់ខ្លួនតាមតម្រូវការ ដើម្បីរួមចំណែកថែមទៀត ដល់ការការពារ និងការលើកស្ទួយសិទ្ធិមនុស្ស សំរាប់ទាំងអស់គ្នា នៅកម្ពុជា។